ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌលេ ៥៤០០ "ស"
ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ ៧១៣០
ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧
សំណុំរឿងស៊ើបសួរលេខ ៤៨៦៧
ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧
សំណុំរឿងជំនុំជម្រះលេខ ១០៦៧
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង ៨ ព្រឹក នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧១៣០ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុផល ភេទប្រុស អាយុ ៤៥ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិត្រពាំងព្រីង ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង អាសយដ្ឋាននៅភូ[redacted] ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ប្រពន្ធឈ្មោះ [redacted] មានកូន ៣ នាក់ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ទោសពីមុន ជាប់ពន្ធនាគារកំណត់ ២៥ ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមសាលក្រមលេខ ៥៤ ក្រ៨៤ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៣២៥ "វ" ផ.ឃ.ផ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

២-ឈ្មោះ [redacted] ម៉ូរ៉ា ហៅ ត័ក្រ ភេទប្រុស អាយុ ៣២ ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិត្រពាំងព្រីង ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង អាសយដ្ឋាននៅ[redacted] ស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង នៅលីវ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted]។

-រត់គេចខ្លួន។

ជាប់ចោទពីបទ **សម្អាតប្រាក់** តាមបញ្ញត្តិមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន

Scanned with CamScanner

ភេរវកម្ម ប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីមុនពេលឃាត់ខ្លួនរហូតដល់បច្ចុប្បន្ន តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២៦៩ "វ" ដ.ដ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឈ្មោះ [redacted] សុផល ត្រូវសមត្ថកិច្ចឃាត់ខ្លួនដោយជាប់ចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត នៅថ្ងៃឃាត់ខ្លួនឈ្មោះ [redacted] សុផល ត្រូវបានសមត្ថកិច្ចដកហូតថ្នាំញៀនប្រភេទមេតំហ្វេតាមីនចំនួន ២៤០០០ គ្រាប់ មានទម្ងន់ ២១៣៤,៥ ក្រាម (ពីរពាន់មួយរយសាមសិបបួនក្បៀសប្រាំក្រាម) , រថយន្ត ០១គ្រឿង ម៉ាក TOYOTA HILUXVIGO ពណ៌ខ្មៅ លេខតួ Nil និងលេខម៉ាស៊ីន 1KD7 687549 ពាក់ផ្លាកលេខភ្នំពេញ 2L-3149 , កាំភ្លើងខ្លីម៉ាក៥៩ ចំនួន ១ ដើម និងបានសម្រេចបិទផ្ទះ, ដីចម្ការនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង, ផ្ទះសំណាក់ សុផល នៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងផ្ទះ ដីចំការស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ហើយត្រូវបានចៅក្រមស៊ើបសួរខេត្តស្ទឹងត្រែង បានចេញដីកាសម្រេចលេខ ១៣២ ព.ស ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ហាមឃាត់ឈ្មោះ [redacted] សុផល មិនឱ្យធ្វើការលក់ដូរ ផ្ទេរសិទ្ធិ ឬអនុប្បទានជួលបញ្ចាំ ដាក់តម្កល់ធានា ដាក់បន្ទុកធ្វើមតិក ធ្វើប្រទានកម្ម ការធ្វើអច្ច័យទានឱ្យអ្នកដទៃនូវ៖ ផ្ទះសំណាក់សុផល និងដីស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង , ផ្ទះ និងដីចំការស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង , ផ្ទះដីចំការស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដោយមានការសង្ស័យថាទ្រព្យសម្បត្តិទាំងនោះបានមកពីផលក្នុងការជួញដូរគ្រឿងញៀន ហើយសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៤៨ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៧ ត្រូវបានចៅក្រមជំនុំជម្រះរាជធានីភ្នំពេញ សម្រេចចេញសាលក្រមលេខ ៥៤ "ក្រ៨ង" ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ផ្តន្ទាទោសលើឈ្មោះ [redacted] សុផល ភេទប្រុស អាយុ៤៥ ឆ្នាំ និងឈ្មោះ [redacted] ប៊ូរ៉ា ហៅ ភ័ក្រ ភេទប្រុស អាយុ ៣២ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២៥ (ម្ភៃប្រាំ) ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ និងរឹបអូសវត្ថុចាប់យក ប្រអប់ដែករាងជ្រុងចំនួន ០១ ដាក់គ្រឿងញៀនប្រភេទមេតំហ្វេតាមីន ទម្ងន់ ២១៣៤,៥ ក្រាម (ពីរពាន់មួយរយសាមសិបបួនក្បៀសប្រាំក្រាម) ស្មើនឹង២៤០០០ គ្រាប់ , សំបកកេះបួនជ្រុងមានអក្សរ Smart ពណ៌ខ្មៅ លាយបៃតងខ្ចីចំនួនមួយ , ថង់ពណ៌សខៀវចំនួន០១ និងទូរស័ព្ទម៉ាកណូគា ចុចពិល ពណ៌ខ្មៅ ចំនួនមួយ ដោយឡែកចំពោះផ្ទះសំណាក់សុផល-ដី ទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

Scanned with CamScanner

ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងរថយន្ត ចំនួន ០១ គ្រឿង ម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខភ្នំពេញ 2L-3249 ពណ៌ខ្មៅលេខម៉ាស៊ីន IKD7687549 ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបង្កក តាមដីកាសម្រេច លេខ ៦៥៥ "ហ" ព្រ.ទ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៧០៤ អ.យ.ឋ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៨៧៩ អ.យ.ឃ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២៦៩ "វ" ដ.ដ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយថា ដីមួយកន្លែងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ម្ដាយខ្លួនបានបែងចែកឱ្យខ្លួន ហើយខ្លួនបានសាងសង់ផ្ទះរស់នៅ និងរៀបចំជាបន្ទប់ជួលស្នាក់នៅជាលក្ខណៈគ្រួសារ មានបន្ទប់សម្រាប់ជួល ៤-៥ បន្ទប់ប៉ុណ្ណោះ ចំពោះប្រាក់សាងសង់ផ្ទះខ្លួនបានយកប្លង់ដីដាក់បញ្ចាំខ្ចីប្រាក់ពីធនាគារ បានមកពីចំណូលរបស់ខ្លួនដែលធ្វើនគរបាល និងបើកអាជីវកម្មលាងម៉ូតូ លាងរថយន្ត ជាឈ្មួញកណ្ដាលទិញលក់ដី ហើយប្រពន្ធខ្លួនគាត់លក់សំលៀកបំពាក់ និងឪពុកម្ដាយបានជួយមួយចំនួន ចំពោះដីចំការទាំងពីរកន្លែងខ្លួនបានទៅកាន់កាប់ដូចប្រជាជនឯទៀតដែរតាំងពីឆ្នាំ១៩៩៧-១៩៩៨ ដោយឡែកចំពោះរថយន្តម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 ខ្លួនបានទិញបង់រំលស់ ហើយឯកសារទិញលក់រក្សាទុកនៅក្នុងរថយន្ត ហើយបានបាត់ពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន។

-សាក្សីឈ្មោះ [redacted]ចាយ ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្ទឹងត្រែង បានឆ្លើយថា ចំពោះដីមួយកន្លែង ស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង មានសារតារដើមជាដីរបស់ឈ្មោះ [redacted] (ជាម្ដាយរបស់ឈ្មោះ [redacted]សុផល) ហើយឈ្មោះ [redacted] បានផ្ទេរឱ្យលោក [redacted]សុផល កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដោយឡែកចំពោះដីចំការពីរកន្លែងទៀតមិនទាន់បានចុះបញ្ជី ខាងមន្ទីរពុំបានដឹងពីសារតារទេ។

-សាក្សីឈ្មោះ [redacted]ណាត ប្រធានមន្ទីរសាធារណៈ និងដឹកជញ្ជូនខេត្តស្ទឹងត្រែង បានឆ្លើយថា ចំពោះរថយន្តម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 ចុះបញ្ជីនៅភ្នំពេញ ដូចពុំមានទិន្នន័យចុះបញ្ជីនៅខេត្តស្ទឹងត្រែង ទេ។

Scanned with CamScanner

-សាក្សីឈ្មោះ [redacted]ឡាន់ សមាជិកក្រុមប្រឹក្សាសាលាសង្កាត់សាមគ្គី បានឆ្លើយថា ដីរបស់លោក [redacted] សុផល ស្ថិតនៅក្នុងភូមិខាំផាន់ ពីមុនជាដីរបស់រដ្ឋ ហើយលោក [redacted] សុផល បានចូលទៅកាន់កាប់ដូចប្រជាជនឯទៀតដែរ។

-សាក្សីឈ្មោះ [redacted]ថា ចៅសង្កាត់រងទី១ សង្កាត់សាមគ្គី បានឆ្លើយថា ដីក្នុងមូលដ្ឋានភូមិខាំផាន់ ខ្លួនពុំបានដឹងរឿងរ៉ាវអ្វីទេ។

-សាក្សីឈ្មោះ [redacted]ម្យ ចៅសង្កាត់ស្រះឫស្សី បានឆ្លើយថា ដីរបស់លោក [redacted] សុផល ស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ លោក [redacted] សុផល បានកាន់កាប់យូរមកហើយ ហើយដីក្នុងតំបន់នោះកំពុងរៀបចំវាស់វែងតំបន់វិនិច្ឆ័យ តែដីរបស់លោក [redacted] សុផល កំពុងមានរឿងរ៉ាវ ទើបគណៈកម្មការមិនបានវាស់វែងចុះបញ្ជីជូនលោក[redacted]សុផល ទេ។

**<u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>**

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងភស្តុតាងឯកសារនានាពាក់ព័ន្ធក្នុងសំណុំរឿងឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុផល និងជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ពិតជាបានប្រព្រឹត្តបទ **សម្អាតប្រាក់** តាមបញ្ញត្តិមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីមុនពេលឃាត់ខ្លួនរហូតដល់បច្ចុប្បន្ន។

ហេតុនេះសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**<u>សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ</u>**

លោកមេធាវី [redacted]នា មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា ការចោទប្រកាន់លើជនជាប់ចោទ ពីបទ សម្អាតប្រាក់ ដោយចាត់ទុកថា ដីផ្ទះសំណាក់ សុផល- ដី ស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង , ដីចំការនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង , ផ្ទះ-ដីចំការទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងរថយន្តមួយ គ្រឿង ម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 ជនជាប់ចោទបានមកពីផលនៃបទល្មើស ប៉ុន្តែតាមភស្តុតាងឃើញថា ដីផ្ទះសំណាក់ សុផល- ដី ស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជនជាប់ចោទទទួលបានពីម្តាយបង្កើតរបស់គាត់ ចំណែកដីចំការនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងផ្ទះ-ដីចំការទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ជនជាប់ចោទបានចូលទៅគាស់រានកាន់កាប់ និងបានធ្វើពាក្យស្នើសុំកាន់កាប់ទៅអាជ្ញាធរ

Scanned with CamScanner

សង្កាត់ត្រឹមត្រូវ ដោយឡែកចំពោះរថយន្តមួយ គ្រឿង ម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 ជនជាប់ចោទបានទិញបង់រំលស់ តែឯកសារទាំងនោះត្រូវបានបាត់ពេលចាប់ ឃាត់ខ្លួនជនជាប់ចោទ។

ហេតុនេះសូមតុលាការពិចារណាសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ និងសម្រេចប្រគល់ទ្រព្យសម្បត្តិរបស់ជនជាប់ចោទ ឱ្យជនជាប់ចោទគ្រប់គ្រងជាកម្មសិទ្ធិវិញ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] សុផល បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុតពីបទចោទ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] សុផល ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងកាន់កាប់ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត តាមបញ្ញត្តិមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ តាមសាលក្រមលេខ ៥៤ ក្រ៨ង ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល បានឆ្លើយថា ដីមួយកន្លែងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ម្តាយខ្លួនបានបែងចែកឱ្យខ្លួន ហើយខ្លួនបានសាងសង់ផ្ទះរស់នៅ និងរៀបចំជាបន្ទប់ជួលស្នាក់នៅជាលក្ខណៈគ្រួសារ មានបន្ទប់សម្រាប់ជួល ៤-៥ បន្ទប់ប៉ុណ្ណោះ ចំពោះប្រាក់សាងសង់ផ្ទះខ្លួនបានយកប្លង់ដីដាក់បញ្ចាំខ្ចីប្រាក់ពីធនាគារ បានមកពីចំណូលរបស់ខ្លួនដែលធ្វើនគរបាល និងបើកអាជីវកម្មលាងម៉ូតូ លាងរថយន្ត ជាឈ្មួញកណ្តាលទិញលក់ដី ហើយប្រពន្ធខ្លួនគាត់លក់សំលៀកបំពាក់ និងឪពុកម្តាយបានជួយមួយចំនួន ចំពោះដីចំការទាំងពីរកន្លែងខ្លួនបានទៅកាន់កាប់ដូចប្រជាជនឯទៀតដែរតាំងពីឆ្នាំ១៩៩៧-១៩៩៨ ដោយឡែកចំពោះរថយន្តម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 ខ្លួនបានទិញបង់រំលស់ ហើយឯកសារទិញលក់រក្សាទុក

Scanned with CamScanner

នៅក្នុងរថយន្ត ហើយបានបាត់ពេលសមត្ថកិច្ចចាប់ឃាត់ខ្លួន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល និងលិខិតបញ្ជាក់លេខ ៩១០ ដនសស.សត ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្ទឹងត្រែង បានបញ្ជាក់ស្របគ្នាថា ដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ សត០០០៣២១ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៩ ពីដំបូងជារបស់ឈ្មោះ [redacted] បានកាន់កាប់តាំងពីឆ្នាំ១៩៩៥ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ ឈ្មោះ [redacted] បានផ្ទេរសិទ្ធិកាន់កាប់ដី និងភូមិគ្រឹះទំហំ ១៥,៤ ម៉ែត្រ X ១៦,៧០ ម៉ែត្រ ឱ្យឈ្មោះ [redacted] សុផល ដូចនេះកំណត់បានថា អចលនវត្ថុផ្ទះសំណាក់ សុផល- ដី ទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង បានបិទតាមកំណត់ហេតុបិទផ្ទះលេខ ០១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សុផល ដោយសុចរិត ពុំមែនជាទ្រព្យបានដោយផលនៃបទល្មើសទេ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល ចម្លើយសាក្សីជាចៅសង្កាត់ ឃើញថាផ្ទះ-ដីចំការ ទីតាំងស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹង , ផ្ទះ-ដីចំការទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងរថយន្តមួយគ្រឿងម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 បញ្ជាក់ពីប្រភពមិនច្បាស់លាស់ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះ [redacted] សុផល បានយកទីតាំងនៃដីចំការដែលបានគ្រប់គ្រង និងរថយន្តធ្វើសកម្មភាពប្រព្រឹត្តបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចមានបញ្ជាក់ក្នុងខ្លឹមសារ នៃសាលក្រមព្រហ្មទណ្ឌលេខ ៥៤ "ក្រ៨ង" ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលអាចកំណត់បានថា ជនជាប់ចោទបានក្លែងសភាវៈពិត តាមរយៈការយកប្រាក់ដែលបានមកពីផលនៃ បទល្មើស ដើម្បីទទួលបានការគ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់នេះ។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទដែលបានធ្វើសកម្មភាពជួញដូរគ្រឿងញៀន ហើយបានបំប្លែងផលដែលបានពីអំពើនេះទៅជាទ្រព្យសម្បត្តិរបស់ខ្លួន មានធាតុផ្សំគ្រប់គ្រាន់ជាបទ សម្អាតប្រាក់ ដូចបញ្ញត្តិតាមមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដូចនេះគប្បីសម្រេចរឹបអូសទ្រព្យសម្បត្តិមាន ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹង , ផ្ទះ-ដីចំការទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងរថយន្តមួយគ្រឿងម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 ជាសម្បត្តិរដ្ឋ។

៦-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្ត្រ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ តាមសាលក្រមព្រហ្មទណ្ឌលេខ ៥៤ "ក្រ៨ង" ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានចូលរួមប្រព្រឹត្តដោយផ្ទាល់ជាមួយជនជាប់ចោទឈ្មោះ [redacted] សុផល ដូចនេះកំណត់បានថា

Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ពិតជាបានចូលរួមប្រព្រឹត្តអំពើបំប្លែងទ្រព្យសម្បត្តិដែលបានមកពីអំពើទុច្ចរិត អំពើនេះមានធាតុផ្សំគ្រប់គ្រាន់ជាបទ សម្អាតប្រាក់ ដូចបញ្ញត្តិ តាមមាត្រាមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

៧-ជនជាប់ចោទឈ្មោះ ឯម សុផល និងជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ជានីតិជន និងជាជនមានសមត្ថភាព និងស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុផល និងជនជាប់ចោទឈ្មោះ [redacted]បូរ៉ា ហៅ ភ័ក្រ្ត ពីបទ **សម្អាតប្រាក់** តាមបញ្ញត្តិមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីមុនពេលឃាត់ខ្លួនរហូតដល់បច្ចុប្បន្ន។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុផល និងជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ពីបទ **សម្អាតប្រាក់** តាមបញ្ញត្តិមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីមុនពេលឃាត់ខ្លួនរហូតដល់បច្ចុប្បន្ន។

១០-ទ្រព្យសម្បត្តិដែលបានបង្កកទុកមាន៖

ក-ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឬស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែងតាមកំណត់ហេតុបិទផ្ទះចំការ លេខ ០២០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ , ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមកំណត់ហេតុបិទផ្ទះចំការ លេខ ០២១ ចុះថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០១៧ និងរថយន្ត ចំនួន ០១ គ្រឿង ម៉ាក TOYOTA HILUX VIGO ពាក់ស្លាកលេខ ភ្នំពេញ 2L-3249 ពណ៌ខ្មៅលេខម៉ាស៊ីន IKD7687549 គប្បីរឹបអូសជាសម្បត្តិរដ្ឋ។

ខ-ផ្ទះសំណាក់សុផល-ដី ទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមកំណត់ហេតុបិទផ្ទះ លេខ ០១៩ ចុះថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០១៧ គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

១១-ជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ពេលប្រព្រឹត្តបទល្មើសរួចបានរត់គេចខ្លួន ក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ ហេតុនេះគប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួន តាមបញ្ញត្តិមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះសម្រេច</u>

១/-ផ្តន្ទាទោស៖

ក/-ឈ្មោះ [redacted]សុផល ភេទប្រុស អាយុ ៤៥ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ ៦

Scanned with CamScanner

(ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល។

ខ/-ឈ្មោះ [redacted] **មូរ៉ា** ហៅ **ភ័ក្រ្ត** ភេទប្រុស អាយុ ៣២ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ២ (ពីរ) ឆ្នាំ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល។

ពីបទ **សម្អាតប្រាក់** តាមបញ្ញត្តិមាត្រា៣ថ្មី និងមាត្រា២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២០ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រព្រឹត្ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីមុនពេលឃាត់ខ្លួនរហូតដល់បច្ចុប្បន្ន។

២/-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] **មូរ៉ា** ហៅ **ភ័ក្រ្ត** ភេទប្រុស អាយុ ៣២ ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ យកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៣/-វត្ថុតាងមាន៖

ក/-ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅចំណុចស្រែសំគង់ ភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមកំណត់ហេតុបិទផ្ទះចំការ លេខ ០២០ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ , ផ្ទះ-ដីចំការ ទីតាំងស្ថិតនៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមកំណត់ហេតុបិទផ្ទះចំការ លេខ ០២១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ និងរថយន្ត មួយ គ្រឿង ម៉ាក TOYOTA HILUX VIGO ពាក់ផ្លាកលេខ ភ្នំពេញ 2L-3249 រឹបអូសជាសម្បត្តិរដ្ឋ។

ខ/-ផ្ទះសំណាក់ សុផល- ដី ទីតាំងស្ថិតនៅភូមិត្រពាំងព្រីង សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តាមកំណត់ហេតុបិទផ្ទះលេខ ០១៩ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ ប្រគល់ឱ្យម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុផល កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បូរ៉ា ហៅ ភ័ក្រ្ត ប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា** [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

Scanned with CamScanner